ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ:...១៥៥ ប្រ.ក......ប.ស្ថ

# ប្រកាស
## ស្តីពី
## ការទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ «បង្កួនសែនជ័យ» នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ស្ថិតនៅក្នុងភូមិសាស្ត្រភូមិបង្កួន ឃុំរៀបរយ ស្រុករវៀង ខេត្តព្រះវិហារ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃ «ព្រៃឡង់»
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១.**_

ត្រូវបានទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ «បង្កួនសែនជ័យ» នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ស្ថិតនៅក្នុងភូមិសាស្ត្រភូមិបង្កួន ឃុំរៀបរយ ស្រុករវៀង ខេត្តព្រះវិហារ។

អគារមរតកតេជោ ដីឡូលេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ: ០២៣ ២៣៩ ០០៤/ ០២៣ ២៣៩ ០០៦

**ប្រការ២._**

សហគមន៍តំបន់ការពារធម្មជាតិ «បង្កនសែនជ័យ» នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» មានផ្ទៃដីសរុបទំហំ ៣១២៩.៦៨ ហិកតា (បីពាន់មួយរយម្ភៃប្រាំបួនកន្លក់សញ្ញាហុកសិបប្រាំបីហិកតា) ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធ កំណត់ដោយចំណុចគោល ដែលមាននិយាមកា (Datum: WGS1984) ដូចក្នុងតារាងខាងក្រោម៖

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 539977 | 1478897 | 17 | 549011 | 1482343 |
| 2 | 540166 | 1478945 | 18 | 548987 | 1482523 |
| 3 | 540272 | 1479025 | 19 | 548895 | 1482607 |
| 4 | 540414 | 1479085 | 20 | 548814 | 1482700 |
| 5 | 540490 | 1479153 | 21 | 548713 | 1482705 |
| 6 | 540788 | 1479160 | 22 | 548719 | 1482733 |
| 7 | 540981 | 1479185 | 23 | 548450 | 1482949 |
| 8 | 541489 | 1479118 | 24 | 548397 | 1482874 |
| 9 | 541888 | 1479272 | 25 | 548355 | 1482714 |
| 10 | 542194 | 1479113 | 26 | 548104 | 1482674 |
| 11 | 542604 | 1479349 | 27 | 547951 | 1482232 |
| 12 | 543170 | 1479665 | 28 | 547652 | 1481913 |
| 13 | 545158 | 1480288 | 29 | 547191 | 1482210 |
| 14 | 548844 | 1481789 | 30 | 542394 | 1484776 |
| 15 | 548828 | 1482078 | 31 | 540049 | 1485109 |
| 16 | 548975 | 1482231 | | | |

**ប្រការ៣._**

ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ «បង្កនសែនជ័យ» ក្នុងគោលបំណងបង្កើនការចូលរួមគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងរួមចំណែកលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**ប្រការ៤._**

សហគមន៍តំបន់ការពារធម្មជាតិ «បង្កនសែនជ័យ» នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន។ សហគមន៍តំបន់ការពារធម្មជាតិ «បង្កនសែនជ័យ» ត្រូវរៀបចំលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ។

**ប្រការ៥.**_

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.**_

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព គ្រប់អគ្គនាយក នៃអគ្គនាយកដ្ឋានចំណុះក្រសួង អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរបរិស្ថានខេត្តព្រះវិហារ និងប្រធានសហគមន៍តំបន់ការពារធម្មជាតិ **"បង្កួនសែនជ័យ"** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែ ពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

<u>កន្លែងទទួល</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តព្រះវិហារ
- ដូចប្រការ៦ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ផែនទី ព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ បឹងតូចសែនជ័យ ក្នុងដែនជម្រកសត្វព្រៃ "ព្រៃឡង់"

## ភូមិសាស្ត្រភូមិបឹងតូច ឃុំរៀបរយ ស្រុករវៀង ខេត្តព្រះវិហារ ផ្ទៃដី៣១២៩,៦៨ហិកតា

ឧបសម្ព័ន្ធ : ប្រកាសលេខ ១២៦២ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ក្រសួងបរិស្ថាន




តារាងកូអរដោនេព្រំប្រទល់សហគមន៍
តំបន់ការពារធម្មជាតិបឹងតូច សែនជ័យ

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 539977 | 1478897 | 16 | 548975 | 1482231 |
| 2 | 540166 | 1478945 | 17 | 549011 | 1482343 |
| 3 | 540272 | 1479025 | 18 | 548987 | 1482523 |
| 4 | 540414 | 1479085 | 19 | 548895 | 1482607 |
| 5 | 540490 | 1479153 | 20 | 548814 | 1482700 |
| 6 | 540788 | 1479160 | 21 | 548713 | 1482705 |
| 7 | 540961 | 1479185 | 22 | 548719 | 1482733 |
| 8 | 541489 | 1479118 | 23 | 548450 | 1482949 |
| 9 | 541888 | 1479272 | 24 | 548397 | 1482874 |
| 10 | 542194 | 1479113 | 25 | 548355 | 1482714 |
| 11 | 542604 | 1479349 | 26 | 548104 | 1482674 |
| 12 | 543170 | 1479665 | 27 | 547951 | 1482232 |
| 13 | 545158 | 1480288 | 28 | 547652 | 1481913 |
| 14 | 548844 | 1481789 | 29 | 547191 | 1482210 |
| 15 | 548828 | 1482078 | 30 | 542394 | 1484776 |
| 16 | 548975 | 1482231 | 31 | 540049 | 1485109 |

សញ្ញាសម្គាល់

Kilometers

Map Coordinate System:
System: UTM, Zone 48
Datum: WGS 1984

មាត្រដ្ឋាន ១:៣៥០០០